ក្រសួងអប់រំ យុវជន និងកីឡា

កុមាររៀន
កុមារចេះ
១២៣

# លេងគប់វង់



### កម្មវិធីជាតិស្តីពីការសិក្សាកម្រិតថ្នាក់ដំបូង នៃក្រសួងអប់រំ យុវជន និងកីឡា


រឿង ៖ **លេងគប់វង់**

និពន្ធដោយ ៖ **លោក ជូ ជីនិត**

រៀបរៀងដោយ ៖ **អ្នកស្រី ហ៊ុយ ឆេងរតនា**

វិចិត្ររូបភាពដោយ ៖ **លោក ជូ ជីនិត**


សៀវភៅនេះត្រូវបានបោះពុម្ពផ្សាយក្រោមអាជ្ញាប័ណ្ណ CC BY-SA ។

សៀវភៅនេះត្រូវបានបង្កើតឡើងសម្រាប់កម្មវិធីកុមាររៀនកុមារចេះ ដែលជាកម្មវិធីជាតិស្តីពីការសិក្សាកម្រិតថ្នាក់ដំបូងរបស់ក្រសួងអប់រំ យុវជន និងកីឡា ដោយមានការគាំទ្រពីជំនួយពីពលរដ្ឋអាមេរិក។

ដើម្បីស្វែងរកសៀវភៅនេះនិងសៀវភៅដទៃទៀតសម្រាប់កុមារ លោកអ្នកអាចចូលទៅកាន់ទំព័រហ្វេសប៊ុកកុមាររៀនកុមារចេះ

www.facebook.com/123komar




ឬគេហទំព័រ តោះអាន ឬទាញយកកម្មវិធីបណ្ណាល័យឌីជីថលតោះអាន

www.LetsReadAsia.org

ចំណានកំពុងលេងបាយឡុកបាយឡ។
ញ៉ាញ់និងដែនកំពុងលេងគប់វង់។



រំពេចនោះ កែវដើរកាត់ទីនោះ។ ចំណាន ឃើញកែវ ក៏ហៅកែវលេងបាយឡុកបាយឡ ជាមួយ។ «កែវ! មកលេងបាយឡុកបាយឡ ដែរទេ?»



ញ៉ាញ់និងដែនឃើញកែវ ក៏ហៅកែវលេងគប់វង់ជាមួយដែរ។

«កែវ! មកលេងគប់វង់ដែរទេ?»



កែវតបវិញ ៖ មិនអីទេចំណាន។
កែវក៏ដើរចេញពីចំណាន។



កែវរត់ទៅលេងគប់វង់ជាមួយញ៉ាញ់និង
ដែនវិញ។ ចំណានក៏អន់ចិត្តនឹងកែវ។



ចំណានឃើញញ៉ាញ់ ដែននិងកែវ
លេងគប់វង់យ៉ាងរីករាយ។





ចំណាននឹកចង់លេងគប់វង់ដែរ។



កែវក៏ហៅចំណានលេងគប់វង់ជាមួយ
ដែរ។ «ចំណាន! តោះលេងគប់វង់ជាមួយ
ពួកយើង។»



ញ៉ាញ់និយាយថា ៖ ចំណានមិនចេះលេង
គប់វង់ទេ។
ដែននិយាយថា ៖ ចំណាននឹងលេងចាញ់
ពួកយើងមិនខាន។



ចំណានតបវិញ ៖ មិនអីទេកែវ។

កែវញញឹម ៖ ចំណាន! កុំអឹមអៀមអី។

តោះ! ទៅលេងគប់វង់ជាមួយពួកយើង។



ចំណានក៏លេងគប់វង់ជាមួយញ៉ាញ់ ដេន និងកែវដែរ។ មុនដំបូង ចំណានគប់មិនចំកំប៉ុងទេ។



ញ៉ាញ់និងដែន និយាយចំអកចំអន់ដាក់ចំណាន។



ចំណានក៏ឈប់លេងគប់វង់ជាមួយពួកគេ។
កែវនិយាយថា ៖ ញ៉ាញ់និងដែនកុំសើច
ចំអកចំអន់លេងអ៊ីចឹង!



កែវនិយាយលួងលោមចំណាន។

«កុំអន់ចិត្តនឹងពួកគេអី។ នេះមកពីចំណាន
មិនទាន់ចេះលេងគប់វង់។»





កែវក៏ជួយណែនាំចំណាន។
ចំណានខិតខំរៀនលេងគប់វង់។



ចំណានគប់ចំកំប៉ុងរហូត។
ចំណានចេះលេងគប់វង់ហើយ!



ញ៉ាញ់និងដែនសរសើរថា ៖ ចំណាន
ពិតជាពូកែលេងគប់វង់មែន។ ពួកគេក៏
លេងយ៉ាងរីករាយ។



ចំណានក៏និយាយ ៖ តោះយើងទៅ
លេងបាយឡុកបាយឡវិញ។
លេងបាយឡុកបាយឡក៏រីករាយដែរ។





មុនដំបូង ញ៉ាញ់ ដែននិង
កែវមិនចេះលេងបាយឡុកបាយឡទេ។
ចំណានក៏ជួយណែនាំពួកគេអំពីរបៀប
លេងបាយឡុកបាយឡ។



ពួកគេក៏ចេះលេងបាយឡុកបាយឡ។ ពួកគេតែងតែលេងបាយឡុកបាយឡ យ៉ាងរីករាយ។





ពួកគេតែងតែលេង គប់វង់យ៉ាងរីករាយដែរ។

# ពន្យល់ពាក្យ

| | | |
|---|---|---|
| ១. **អឹមអៀម** | : | ដែលនិយាយស្ទើរមិនហើបមាត់ |
| ២. **ចំអកចំអន់** | : | និយាយលេងឱ្យអន់ចិត្ត |
| ៣. **លួងលោម** | : | និយាយពាក្យទន់ផ្អែមល្ហែមឱ្យគេសប្បាយចិត្តវិញ |
| ៤. **អន់ចិត្ត** | : | តូចចិត្ត ឬមិនសូវសប្បាយចិត្ត |
| ៥. **ខិតខំ** | : | ប្រឹងប្រែង |



# សំណួរ

១. តើចំណានកំពុងលេងអ្វី? តើញ៉ាញ់និងដែនកំពុងលេងអ្វី?

២. ហេតុអ្វីបានជាចំណានអន់ចិត្តនឹងកែវ?

៣. តើចំណានបានរៀនលេងគប់វង់ដែរឬទេ? តើនាងចេះលេងគប់វង់បានល្អដែរឬទេ? ហេតុអ្វី?

៤. ចុះកូនវិញ តើកូនចូលចិត្តលេងល្បែងអ្វីជាងគេ? ហេតុអ្វី?





បន្ទាប់ពីរៀនចប់មេរៀនទី៧ **«ពាក្យប្រកបនឹង ម យ រ»** នៃសៀវភៅថ្នាក់ទី២ សិស្សនឹងអាចអានសៀវភៅរឿងនេះបានដោយខ្លួនឯង ដោយពុំចាំបាច់មានអ្នកជទៃជួយឡើយ។

ទោះជាយ៉ាងណា សិស្សថ្នាក់ទី១ ក៏អាចអានសៀវភៅរឿងនេះជាមួយគ្រូបានដែរ ដោយពួកគេអាចមើលនិងរៀបរាប់អំពីរូបភាពនៅក្នុងសៀវភៅរឿងនេះ ហើយអានពាក្យនិងតួអក្សរដែលពួកគេស្គាល់។

សូមចងចាំថា នៅពេលសិស្សចាប់ផ្តើមអានសៀវភៅកាន់តែឆាប់ គឺកាន់តែប្រសើរសម្រាប់ពួកគេ!

កម្មវិធីជាតិស្តីពីការសិក្សាកម្រិតថ្នាក់ដំបូងនៃ
ក្រសួងអប់រំ យុវជន និងកីឡា

9 789924 560357

បោះពុម្ពឆ្នាំ២០២១